ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២២៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីសរុបទំហំ ២០.៣៣៣ ហិកតា ដែលក្នុងនោះ ទំហំ ៣៧៥៦ ហិកតា កាត់ចេញពីគម្របព្រៃឈើ ២០០២ និងទំហំ ១៦.៥៧៧ ហិកតា ចេញពី តំបន់ការពារទេសភាពបន្ទាយឆ្មារ ដើម្បីធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ១៩.៥៥៥ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៥.៧៩៧ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះ ជាក់ស្តែង និងទំហំ ៧៧៨ ហិកតា រក្សាទុកជាដីសហគមន៍តំបន់ ការពារធម្មជាតិ នៅស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១១២/១០០៩ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០១២
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ២១៣៩ ខបជ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបន្ទាយមានជ័យ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ដីសរុបទំហំ ២០.៣៣៣ ហិកតា ដែលក្នុងនោះ ទំហំ ៣.៧៥៦ ហិកតា កាត់ចេញពីគម្របព្រៃឈើ ២០០២ និងទំហំ ១៦.៥៧៧ ហិកតា ចេញពីតំបន់ការពារទេសភាពបន្ទាយឆ្មារ ត្រង់មាត្រា ២ ចំណុច ៣ លេខរៀងទី ១៩ នៃព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ១៩.៥៥៥ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ប្រើប្រាស់ និងដាំដុះដាក់ស្តែង និងទំហំ ៧៧៨ ហិកតា រក្សាទុកជាដីសហគមន៍តំបន់ការពារធម្មជាតិ នៅឃុំគោករមៀតឃុំគំរូ និងឃុំបន្ទាយឆ្មារស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ដែលស្ថិតនៅក្នុងភូមិ ដូចខាងក្រោម៖

- ផ្ទៃដីសរុបទំហំ ៩.៣៩៤ ហិកតា ដែលក្នុងនោះ កាត់ចេញពីគម្របព្រៃឈើ ២០០២ ទំហំ ១០៩ ហិកតា និងពីតំបន់ការពារទេសភាពបន្ទាយឆ្មារ ទំហំ ៩.២៨៥ ហិកតា ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋនូវទំហំ ៨.៨២៩ ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៥៦៥ ហិកតា រក្សាទុកជាដីសហគមន៍តំបន់ការពារធម្មជាតិ នៅតំបន់ភូមិ ០៥ ជាប់ព្រំគ្នា រួមមាន ភូមិតាម៉ាំង ភូមិបឹងតាស្រី ភូមិតាឡី ភូមិថ្មី និងភូមិកណ្តាល ឃុំគោករមៀត តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ។

- ផ្ទៃដីទំហំ ៥.៧០៤ ហិកតា កាត់ចេញពីតំបន់ការពារទេសភាពបន្ទាយឆ្មារ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៥.៤៩១ ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ២១៣ ហិកតា រក្សាទុកជាដីសហគមន៍តំបន់ការពារធម្មជាតិ នៅតំបន់ភូមិ ០៣ ជាប់ព្រំគ្នា រួមមានភូមិព្រៃវែង ភូមិតាយឹង និងភូមិអណ្ដូងខ្លុង ឃុំគំរូ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ។

- ផ្ទៃដីសរុបទំហំ ៥.២៣៥ ហិកតា ដែលក្នុងនោះ កាត់ចេញពីគម្របព្រៃឈើ ២០០២ ទំហំ ៣.៦៤៧ ហិកតា និងពីតំបន់ការពារទេសភាពបន្ទាយឆ្មារ ទំហំ ១.៥៨៨ ហិកតា ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅតំបន់ភូមិ ០៣ ជាប់ព្រំគ្នា រួមមាន ភូមិបន្ទាយឆ្មារត្បូង ភូមិថ្មដែកកេះ និងភូមិព្រៃចង្ការ ឃុំបន្ទាយឆ្មារ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ។

**មាត្រា ២.**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ធំ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ៥.៧៩៧ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្ដែង នៅភូមិ ឃុំ ដូចខាងក្រោម៖

- ផ្ទៃដីកាត់ចេញពីគម្របព្រៃឈើ ២០០២ និងពីតំបន់ការពារទេសភាពបន្ទាយឆ្មារ ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ៣.១៣៦ គ្រួសារ នៅតំបន់ភូមិ ០៥ ជាប់ព្រំគ្នា រួមមានភូមិ តាម៉ាំង ភូមិបឹងតាស្រី ភូមិតាឡី ភូមិថ្មី និងភូមិកណ្ដាល ឃុំគោករមៀត
- ផ្ទៃដីកាត់ចេញពីតំបន់ការពារទេសភាពបន្ទាយឆ្មារ ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១.៦៤៣ គ្រួសារ នៅតំបន់ភូមិ ០៣ ជាប់ព្រំគ្នា រួមមាន ភូមិព្រៃវែង ភូមិតាយឹង និងភូមិអណ្ដូងខ្លុង ឃុំគំរូ
- ផ្ទៃដីកាត់ចេញពីគម្របព្រៃឈើ ២០០២ និងពីតំបន់ការពារទេសភាពបន្ទាយឆ្មារ ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ១.០១៨ គ្រួសារ នៅតំបន់ភូមិ ០៣ ជាប់ព្រំគ្នា រួមមាន ភូមិបន្ទាយឆ្មារត្បូង ភូមិថ្មដែកកេះ និងភូមិព្រៃចង្ការ ឃុំបន្ទាយឆ្មារ

**មាត្រា ៣ ..**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្ដែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបន្ទាយមានជ័យ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ទាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គមនៅក្នុងមូលដ្ឋាន ។

**មាត្រា ៤..**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ [illegible] ឆ្នាំ ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការ រាជរដ្ឋាភិបាល
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ...អនក្រ.បក ចុះថ្ងៃទី...០៣...ខែ...ឧសភា... ឆ្នាំ២០១២

ស្តីពីការកាត់ដីសរុបទំហំ ២០.៣៣៣ ហិកតា ដែលក្នុងនោះ ទំហំ ៣៧៥៦ ហិកតា កាត់ចេញពីគម្របព្រៃឈើ និង ទំហំ ១៦.៥៧៧ ហិកតា ចេញពីតំបន់ការពារទេសភាពបន្ទាយឆ្មារ ដើម្បីធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ១៩.៥៥៥ ហិកតា សម្រាប់ធ្វើប្រទានកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៥៧៩៧ គ្រួសារ ដែលបានកាន់កាប់ប្រើប្រាស់ និងដោះដាក់ស្លេង និងទំហំ ៧៧៨ ហិកតា រក្សាទុកជាដីសហគមន៍តំបន់ការពារធម្មជាតិ នៅស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ




**កំណត់សំគាល់**

- ចំណុចគោល លេខ1 ដល់ លេខ144
- ចំណុចលំអិតមាននៅក្នុងឧបសម្ព័ន្ធជូនភ្ជាប់
- ព្រំតំបន់ដីកាត់ចេញពីផែនទីគម្របព្រៃឈើឆ្នាំ២០០២ ទំហំ3756 ha ដែលមានគ្រួសារចំនួន ៧០៧ គ្រួសារ
- ព្រំតំបន់ដីកាត់ចេញពីតំបន់ការពារទេសភាពបន្ទាយឆ្មារ ទំហំ15799 ha ដែលមានគ្រួសារចំនួន ៥០៩០ គ្រួសារ
- ព្រំប្រទល់សហគមន៍តំបន់ការពារធម្មជាតិ ទំហំ788 ha

**វាស់វែងដោយឧបករណ៍**

- GARMIN GPSmap 62s (UTM ZONE 48N Datum WGS 1984)

Meters: 0, 2,200, 4,400, 8,800

| Code | X_Coor | Y_Coor | Code | X_Coor | Y_Coor | Code | X_Coor | Y_Coor | Code | X_Coor | Y_Coor | Code | X_Coor | Y_Coor | Code | X_Coor | Y_Coor |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| Projection UTM Zone 48N Datum WGS84 | | | | | | | | | Projection UTM Zone 48N Datum WGS84 | | | | | | | | |
| 1 | 273645 | 1558126 | 25 | 295871 | 1555097 | 49 | 303450 | 1559828 | 73 | 293564 | 1551715 | 97 | 273747 | 1552878 | 121 | 276176 | 1555376 |
| 2 | 274152 | 1558253 | 26 | 296501 | 1554831 | 50 | 304844 | 1559700 | 74 | 293240 | 1551728 | 98 | 273959 | 1552870 | 122 | 275822 | 1556124 |
| 3 | 280605 | 1558187 | 27 | 296547 | 1554517 | 51 | 306461 | 1559304 | 75 | 293208 | 1551444 | 99 | 273678 | 1553390 | 123 | 275969 | 1556658 |
| 4 | 282574 | 1558416 | 28 | 297075 | 1554336 | 52 | 305663 | 1557646 | 76 | 293135 | 1551193 | 100 | 273479 | 1553820 | 124 | 276144 | 1557115 |
| 5 | 282979 | 1558619 | 29 | 297435 | 1554412 | 53 | 305744 | 1557429 | 77 | 292879 | 1550803 | 101 | 273242 | 1554129 | 125 | 276206 | 1557629 |
| 6 | 282992 | 1557560 | 30 | 297650 | 1554259 | 54 | 305690 | 1556648 | 78 | 292644 | 1550879 | 102 | 273102 | 1554371 | 126 | 276269 | 1558144 |
| 7 | 286894 | 1556331 | 31 | 297634 | 1553798 | 55 | 305532 | 1555775 | 79 | 292433 | 1549679 | 103 | 273093 | 1554842 | 127 | 276770 | 1558141 |
| 8 | 285804 | 1554512 | 32 | 297766 | 1553412 | 56 | 304685 | 1555676 | 80 | 291583 | 1549791 | 104 | 273124 | 1554953 | 128 | 277277 | 1558139 |
| 9 | 285334 | 1553168 | 33 | 297929 | 1553218 | 57 | 303127 | 1556259 | 81 | 289269 | 1544847 | 105 | 273198 | 1555093 | 129 | 276912 | 1556697 |
| 10 | 288020 | 1553055 | 34 | 298345 | 1553155 | 58 | 302673 | 1554788 | 82 | 289230 | 1542967 | 106 | 273202 | 1555435 | 130 | 279461 | 1552125 |
| 11 | 289358 | 1552542 | 35 | 298296 | 1553625 | 59 | 301801 | 1554543 | 83 | 285613 | 1544704 | 107 | 273252 | 1555542 | 131 | 279277 | 1552642 |
| 12 | 289453 | 1552761 | 36 | 298287 | 1553835 | 60 | 300108 | 1554803 | 84 | 283061 | 1547439 | 108 | 273311 | 1555689 | 132 | 279200 | 1553124 |
| 13 | 289878 | 1552556 | 37 | 298323 | 1554113 | 61 | 300508 | 1553750 | 85 | 280537 | 1548422 | 109 | 273373 | 1555867 | 133 | 281952 | 1553124 |
| 14 | 290088 | 1552791 | 38 | 298539 | 1555029 | 62 | 299748 | 1553851 | 86 | 279073 | 1548365 | 110 | 273394 | 1555946 | 134 | 282021 | 1552626 |
| 15 | 290766 | 1552504 | 39 | 298614 | 1555154 | 63 | 299737 | 1552983 | 87 | 277912 | 1548522 | 111 | 273553 | 1556183 | 135 | 281952 | 1552124 |
| 16 | 291042 | 1552990 | 40 | 299575 | 1555635 | 64 | 299607 | 1552369 | 88 | 276503 | 1550181 | 112 | 274695 | 1552063 | 136 | 289148 | 1548123 |
| 17 | 292457 | 1553213 | 41 | 300393 | 1556006 | 65 | 299416 | 1552018 | 89 | 275124 | 1551142 | 113 | 274390 | 1552249 | 137 | 286540 | 1550025 |
| 18 | 292478 | 1554205 | 42 | 301276 | 1556270 | 66 | 297987 | 1552098 | 90 | 274897 | 1550253 | 114 | 275217 | 1552978 | 138 | 286570 | 1550490 |
| 19 | 293726 | 1553707 | 43 | 301357 | 1556647 | 67 | 297955 | 1552552 | 91 | 274591 | 1550378 | 115 | 274817 | 1552978 | 139 | 287501 | 1550127 |
| 20 | 294290 | 1554514 | 44 | 301992 | 1557689 | 68 | 297711 | 1552745 | 92 | 274457 | 1551110 | 116 | 274901 | 1553470 | 140 | 288061 | 1549846 |
| 21 | 294434 | 1555000 | 45 | 302126 | 1557936 | 69 | 297041 | 1551948 | 93 | 274156 | 1552010 | 117 | 274985 | 1553962 | 141 | 288684 | 1549433 |
| 22 | 294458 | 1555278 | 46 | 302241 | 1558518 | 70 | 296577 | 1552157 | 94 | 273924 | 1552129 | 118 | 275219 | 1554624 | 142 | 289132 | 1549114 |
| 23 | 294560 | 1555278 | 47 | 302997 | 1559061 | 71 | 296536 | 1551853 | 95 | 273778 | 1552244 | 119 | 275447 | 1555000 | 143 | 289141 | 1548423 |
| 24 | 294559 | 1555076 | 48 | [illegible] | 1559252 | 72 | 294700 | 1551776 | 96 | 273596 | 1552613 | 120 | 275676 | 1555376 | 144 | 292566 | 1551983 |